# San Joaquin Regional Transit District (RTD)

# សេចក្តីបញ្ជាក់អំពី គោលនយោបាយ ជំពូក VI

San Joaquin RTD ប្រព្រឹត្តចំពោះអតិថិជនរបស់ខ្លួនដោយការគោរព ភាពសុចរិត និងភាពស្មោះត្រង់។ ភ្នាក់ងារដឹកជញ្ជូនក្នុងតំបន់ San Joaquin ( RTD) ដំណើរការកម្មវិធីរបស់ខ្លួនដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជំនឿ ជាតិកំណើត សាសនា ភេទ ទំនោរផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពវេជ្ជសាស្ត្រ ឬពិការភាពអ្វីឡើយ អនុលោមតាមជំពូក VI នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋ (Civil Rights Act) និងក្រមរដ្ឋប្បវេណី California Civil Code ផ្នែក 51(b) ឬច្បាប់ជាធរមានផ្សេងទៀត។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ការិយាល័យរដ្ឋបាលរបស់ RTD តាមរយៈលេខទូរសព្ទ (209) 943-1111 ឬអ៊ីមែលទៅកាន់អាសយដ្ឋាន comments@sjRTD.com។

## សេចក្តីបញ្ជាក់អំពី គោលនយោបាយ ជំពូក VI របស់ San Joaquin RTD

ជំពូក VI ច្បាប់ស្តីពីសិទ្ធិពលរដ្ឋឆ្នាំ1964 ចែងថា “គ្មានបុគ្គលណាម្នាក់នៅក្នុងសហរដ្ឋអាមេរិក ត្រូវទទួលរងនូវការច្រានចោលសិទ្ធិចូលរួម បដិសេធន៍មិនផ្តល់ អត្ថប្រយោជន៍ ឬត្រូវទទួលរងនូវការរើសអើងក្រោមកម្មវិធី ឬសកម្មភាពនៃការទទួលបានជំនួយហិរញ្ញវត្ថុរបស់សហព័ន្ធ ដោយផ្អែកលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ឬជាតិកំណើតអ្វីនោះឡើយ។ ”San Joaquin RTD ប្តេជ្ញាចិត្តក្នុងការគោរពទៅតាមលក្ខខណ្ឌតម្រូវនៃជំពូក VI នៅក្នុងគ្រប់កម្មវិធី និងសកម្មភាពទាំងអស់ដែលផ្តល់មូលនិធិដោយសហព័ន្ធ។

## ការដាក់ពាក្យបណ្តឹងស្របតាមជំពូក VI

បុគ្គលទាំងឡាយណាដែលគិតថាពួកគេរងគ្រោះដោយទង្វើនៃការរើសអើងមិនត្រឹមត្រូវតាមច្បាប់ក្រោមជំពូក VI នេះ អាចដាក់ពាក្យបណ្តឹងទៅកាន់ San Joaquin RTD បាន។ សម្រាប់ព័ត៌មានស្តីពីការដាក់ពាក្យបណ្តឹងណាមួយ សូមទាក់ទងទៅកាន់ការិយាល័យរដ្ឋបាលរបស់ San Joaquin RTD។ ពាក្យបណ្តឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវប្រគល់ជូនក្នុងរយៈពេល 180 ថ្ងៃក្រោយកាលបរិច្ឆេទនៃការកើតមានការរើសអើងដែលបានចោទប្រកាន់នេះ។

អ៊ីមែល៖ comments@sjRTD.com

ទូរសព្ទ៖ (209) 943-1111

ទូរសារ៖ (209) 948-8516

សំបុត្រប្រៃសណីយ៍៖ San Joaquin Regional Transit District (RTD)

ផ្ញើជូន៖ Title VI Administrator

P.O.Box 201010

Stockton, CA 95201

sjRTD.com | (209) 943-1111

March 16, 2020